ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ អង្គារ ៥ រោច ខែ មិគសិរ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២២*

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**ជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ជាមួយឯកឧត្តម** Joseph Scheuer, Resident Coordinator
**នៃទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំកម្ពុជា**

នៅរសៀលថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២២ វេលាម៉ោង ៣:៣០ នាទីរសៀល នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួប **ឯកឧត្តម** Joseph Scheuer, Resident Coordinator នៃទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំកម្ពុជា ដើម្បីពិភាក្សាការងារអំពីកិច្ចសហប្រតិបត្តិការ រវាងប្រព័ន្ធអង្គការសហប្រជាជាតិ (UN System) និងកម្ពុជា ក្នុងឱកាសដែល **ឯកឧត្តម** ទើបបានចូលកាន់តំណាងថ្មី កាលពីខែតុលា ឆ្នាំ ២០២២ កន្លងទៅនេះ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវសេចក្តីរីករាយ និងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ **ឯកឧត្តម** Joseph Scheuer ដែលត្រូវបានតែងតាំងជា Resident Coordinator ថ្មីនៃទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំកម្ពុជា ។ ជាមួយគ្នានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់អំពីកិច្ចសហប្រតិបត្តិការដ៏ល្អ និងរឹងមាំ រវាងរាជរដ្ឋាភិបាលកម្ពុជា និងប្រព័ន្ធអង្គការសហប្រជាជាតិ ពិសេស ការចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ នៅកម្ពុជា ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានគូសរំលេចផងដែរថា រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យប្រើប្រាស់នូវ “ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣” ជាមួយនឹងទស្សនវិស័យនៃការចាកចេញពីវិបត្តិនៃជំងឺកូវីដ-១៩ ក្នុងភាពរឹងមាំ និងការវិលត្រលប់ទៅរកមាគ៌ានៃកំណើន និងការអភិវឌ្ឍប្រកបដោយចីរភាព ។ យុទ្ធសាស្ត្រនេះ នឹងដើរតួនាទីជាផែនទីបង្ហាញផ្លូវ និងជាកម្លាំងចលករដ៏មានប្រសិទ្ធភាព សម្រាប់ការពង្រឹងសក្តានុពលនៃចន្ទល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ឱ្យរស់រវើកឡើងវិញ ក៏ដូចជាចាប់យកឱ្យបាន នូវកាលានុវត្តភាពថ្មីៗ ដែលកំពុងលេចឡើងស្របនឹងនិន្នាការតំបន់ និងសកល ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និង ដើម្បីកសាងភាពធន់ដ៏រឹងមាំនៃសង្គម-សេដ្ឋកិច្ចកម្ពុជា ។ ជាមួយគ្នានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណចំពោះការគាំទ្ររបស់ប្រព័ន្ធអង្គការសហប្រជាជាតិ ក្នុងការចូលរួមជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ជាពិសេស ការផ្តល់ជំនួយបច្ចេកទេសលើវិស័យគាំពារសង្គមដែលជាវិស័យអាទិភាពមួយរបស់កម្ពុជា ដើម្បីឈានទៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការចាកចេញពីឋានៈប្រទេស

ដែលមានការអភិវឌ្ឍតិចតួច ហើយក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។

ជាការឆ្លើយតប, **ឯកឧត្តម** Joseph Scheuer ក៏បានសម្តែងនូវសេចក្តីរីករាយជាអនេក ដោយបានមកបំពេញភារកិច្ចនៅព្រះរាជាណាចក្រកម្ពុជាជាថ្មីម្តងទៀត និងបានសម្តែងនូវការកោតសរសើរ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលសម្រេចបាននូវសមិទ្ធផលផ្លែផ្កាជាច្រើនឥតគណនា ពិសេស ការដាក់ចេញនូវវិធានការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ប្រកបដោយជោគជ័យ ដោយបានការពារសុខភាព និងអាយុជីវិតរបស់ប្រជាជន, រក្សាលំនឹងសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន ។ **ឯកឧត្តម** Joseph Scheuer បានបង្ហាញជំហរមុតមាំក្នុងការបន្តផ្តល់ការគាំទ្រដល់វិស័យគាំពារសង្គម និងបន្តកិច្ចសហការយ៉ាងជិតស្និតជាមួយភាគីពាក់ព័ន្ធទៅលើវិស័យនេះផងដែរ ។ ទន្ទឹមនេះ, **ឯកឧត្តម** Joseph Scheuer ក៏បានបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ប្រព័ន្ធអង្គការសហប្រជាជាតិ ក្នុងការគាំទ្រកម្ពុជាឱ្យសម្រេចបាននូវរបៀបវារៈស្តីពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០៣០ តាមរយៈ **“ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអង្គការសហប្រជាជាតិ (UN Cooperation Framework) ថ្មី ឆ្នាំ២០២៤-២០២៨”** ។ **ឯកឧត្តម** Joseph Scheuer បានមានប្រសាសន៍ផងដែរថា អង្គការសហប្រជាជាតិនឹងសហការជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលដើម្បីរៀបចំ **“ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអង្គការសហប្រជាជាតិ ឆ្នាំ ២០២៤-២០២៨”** ក្រោមក្របខណ្ឌនៃយន្តការដែលមានស្រាប់របស់រាជរដ្ឋាភិបាល ដើម្បីធានាឱ្យបាននូវការឆ្លើយតបទៅនឹងទិសដៅ និងអាទិភាពនៃការអភិវឌ្ឍរបស់កម្ពុជា ស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងអាណត្តិថ្មី ។

ជាថ្មីម្តងទៀត, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវសេចក្តីរីករាយ និងមោទនភាពចំពោះកិច្ចសហប្រតិបត្តិការយ៉ាងរឹងមាំ រវាងប្រព័ន្ធអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ហើយបានសម្តែងនូវការស្វាគមន៍ និងការត្រៀមខ្លួនរួចជាស្រេច ក្នុងការសហការជាមួយអង្គការសហប្រជាជាតិ រៀបចំ **“ក្របខ័ណ្ឌកិច្ចសហប្រត្តិការអង្គការសហប្រជាជាតិ ឆ្នាំ ២០២៤-២០២៨”** ឱ្យស្របទៅតាមយុទ្ធសាស្ត្រ និងទិសដៅជាអាទិភាពរបស់រាជរដ្ឋាភិបាល ។ បន្ថែមលើនេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានស្នើឱ្យអង្គការសហប្រជាជាតិសហការជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀត ដើម្បីផ្តល់ការគាំទ្រដល់កម្ពុជាក្នុងបេសកកម្មបោសសម្អាតមីន ដើម្បីឈានដល់ការសម្រេចឱ្យបាននូវគោលបំណងនៃផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ និងការសម្រេចបានគោលដៅ **“កម្ពុជាគ្មានមីន”** នៅត្រឹមឆ្នាំ ២០២៥ ។

ជាទីបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការដ៏ល្អរបស់ប្រព័ន្ធអង្គការសហប្រជាជាតិ និងសង្ឃឹមយ៉ាងមុតមាំថា បេសកកម្មការងាររបស់ **ឯកឧត្តម** Joseph Scheuer នឹងរួមចំណែកដល់ការបន្តពង្រឹង និង ពង្រីកកិច្ចសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយប្រព័ន្ធអង្គការសហប្រជាជាតិឱ្យកាន់តែរឹងមាំបន្ថែមទៀត ។

####